ព្រឹត្តិបត្រព័ត៌មាន
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)
គ.ជ.ប NEC BULLETIN
លេខ ៣ ចេញផ្សាយថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣
Issue 3 : 18 / 5 / 2023

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

## គ.ជ.ប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធស្តីពី បច្ចុប្បន្នភាពនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣



ឯកឧត្តម មាន សទិ សមាជិក គ.ជ.ប

នាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣ នៅទីស្តីការគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោតក្រោមអធិបតីភាព ឯកឧត្តម មាន សទិ សមាជិក គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដែលមានប្រធានបទ



តនៅទំព័រទី២

**មាតិកា៖** ទំព័រ

- គ.ជ.ប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធស្តីពី បច្ចុប្បន្នភាពនៃការចុះបញ្ជីគណបក្សនយោបាយ ............... ១
- គ.ជ.ប បើកវគ្គបណ្តុះបណ្តាលស្តីពី ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ........... ៤
- វគ្គបណ្តុះបណ្តាលស្តីពីការឃោសនាបោះឆ្នោតរយៈពេល ២ថ្ងៃ ត្រូវបានបិទបញ្ចប់ ............................................................. ៦
- ចំនួនអាសនៈនៃរដ្ឋសភា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅតាមមណ្ឌល .... ៨
- បេក្ខជនឈរឈ្មោះបោះឆ្នោត សហព័ទ្ធ និងកូនរបស់បេក្ខជន អាចស្នើសុំប្តូរការិយាល័យបោះឆ្នោត ......................... ៩
- សិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ........... ១០
- តំណាង គ.ជ.ប ជួបពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុនហ្គូហ្គល (Google) ................................................ ១៣
- រូបភាពសកម្មភាពនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជន ........... ១៤

តមកពីទំព័រទី១ **គ.ជ.ប រៀបចំកិច្ចប្រជុំ ...**

ស្តីពី បច្ចុប្បន្នភាពនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ បច្ចុប្បន្នភាពចំនួនអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត។

ឯកឧត្តម **មាន សទិ** បានមានប្រសាសន៍ថា រហូតមកដល់ថ្ងៃចុងក្រោយ (ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣) នៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានគណបក្សនយោបាយចំនួន ២០ បានដាក់ពាក្យសុំចុះបញ្ជីគណបក្សនៅ គ.ជ.ប។ ក្នុងនោះមានគណបក្សនយោបាយចំនួន ១១ ត្រូវបាន គ.ជ.ប សម្រេចទទួល



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

ស្គាល់ជាផ្លូវការ និងគណបក្សនយោបាយចំនួន ៩ ផ្សេងទៀតកំពុងឋិតក្នុងការត្រួតពិនិត្យ និងរង់ចាំការប្រជុំសម្រេចដោយ គ.ជ.ប។

ពាក់ព័ន្ធនឹងអ្នកសង្កេតការណ៍ ឯកឧត្តម **មាន សទិ** បានជម្រាបជូនថា គិតត្រឹមថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣ គ.ជ.ប បានទទួលស្គាល់អ្នកសង្កេតការណ៍ជាតិ សរុបចំនួន ១០.១៣០នាក់ ក្នុងនោះស្ត្រីមានចំនួន ៥.០៥៦នាក់ ហើយ គ.ជ.ប ពុំទាន់បានទទួលពាក្យសុំសង្កេតការណ៍របស់អ្នកសង្កេតការណ៍អន្តរជាតិ ពីស្ថាប័ន ឬប្រទេសណាមួយទេ។ ឯកឧត្តម បានបន្តថា អ្នកសង្កេតការណ៍បោះឆ្នោតរួមមាន៖

- អ្នកសង្កេតការណ៍ជាតិ គឺជាជនជាតិខ្មែរ ឬជនបរទេស ដែលជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីនៅក្រសួង-មហាផ្ទៃ និងអនុញ្ញាតដោយ គ.ជ.ប



**សកម្មភាពក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ**

- អ្នកសង្កេតការណ៍អន្តរជាតិ គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានា ដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា ហើយនិងបានអនុញ្ញាតដោយ គ.ជ.ប
- អ្នកសង្កេតការណ៍ជាតិចល័តសំដៅដល់ថ្នាក់ដឹកនាំ ឬមន្ត្រីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលសាមីអង្គភាពស្នើសុំ និងត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការបោះឆ្នោតនៅទូទាំងប្រទេស។

ចំពោះតួនាទីរបស់អ្នកសង្កេតការណ៍ ឯកឧត្តម **មាន សទិ** បានបញ្ជាក់ជូនថា អ្នកសង្កេតការណ៍មានសិទ្ធិធ្វើសកម្មភាពសង្កេតការណ៍បោះឆ្នោតដោយឯករាជ្យ។ អ្នកសង្កេតការណ៍ជាតិអាចធ្វើដំណើរសង្កេតការណ៍ក្នុងរាជធានី ខេត្តដែលអង្គការ



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**



តំណាងភាគីពាក់ព័ន្ធមានសំណួរក្នុងកិច្ចប្រជុំ

មិនមែនរដ្ឋាភិបាល ឬសមាគមនោះ បានស្នើសុំតែប៉ុណ្ណោះ លើកលែងតែអ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេស ដែលត្រូវបានអនុញ្ញាត និងផ្តល់បណ្ណសម្គាល់ដោយ គ.ជ.ប។ ឯកឧត្តមបានបន្តថា ចំពោះអ្នកសង្កេតការណ៍អន្តរជាតិ អាចធ្វើដំណើរគ្រប់ទីកន្លែងក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយពុំចាំបាច់សុំការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួន។ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ អ្នកសង្កេតការណ៍ត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោត និងអាជ្ញាធរដែនដីពាក់ព័ន្ធដើម្បីជួយដោះស្រាយទាន់ពេលវេលា។

ឯកឧត្តម **មាន សទិ** បានបញ្ជាក់ជូនទៀតថា សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត និងបម្រាមចំពោះអ្នកសង្កេតការណ៍បោះឆ្នោត មានចែងនៅក្នុងសៀវភៅក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត។

មានសំណួររបស់ភាគីចូលរួមក្នុងកិច្ចប្រជុំ ពាក់ព័ន្ធនឹងនីតិវិធីនៃការពិនិត្យពាក្យសុំចុះបញ្ជីរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ ការដកខ្លួនចេញរបស់បេក្ខជនដែលបានឈរឈ្មោះបោះឆ្នោត និងការចូលរួមរបស់អ្នកសង្កេតការណ៍អន្តរជាតិ។



តំណាងភាគីពាក់ព័ន្ធមានសំណួរក្នុងកិច្ចប្រជុំ

តំណាង គ.ជ.ប បានឆ្លើយក្នុងអង្គប្រជុំនោះថា គ.ជ.ប ពិនិត្យពាក្យសុំចុះបញ្ជីរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានពាក្យសុំ។ ក្នុងករណី គ.ជ.ប យល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជូនសាមីគណបក្សនយោបាយ។ ក្នុងករណី គ.ជ.ប ពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយពុំបានបំពេញលក្ខខណ្ឌណាមួយដូចមានចែងក្នុងច្បាប់ បទបញ្ជា និងនីតិវិធី គ.ជ.ប ត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយវិញ ដើម្បីបំពេញបន្ថែម។ គណបក្សនយោបាយត្រូវបំពេញលក្ខខណ្ឌដែលខ្វះខាតយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃដែលសាមីគណបក្សនយោបាយបានទទួលលិខិតជូនដំណឹងពី គ.ជ.ប។



តំណាងភាគីពាក់ព័ន្ធមានសំណួរក្នុងកិច្ចប្រជុំ

ករណីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ គ.ជ.ប បានសុំការបញ្ជាក់ពីក្រសួងយុត្តិធម៌ អំពីភាពមាននីតិសម្បទាឡើងវិញរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ដោយក្រសួងយុត្តិធម៌បានឆ្លើយបញ្ជាក់មក គ.ជ.ប វិញថា ឈ្មោះ **រ៉ុង ឈុន** មិនទាន់មាននីតិសម្បទាឡើងវិញទេ។ ដូចនេះ ឈ្មោះ **រ៉ុង ឈុន** គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ។

ចំពោះការដកខ្លួនចេញពីបេក្ខជនឈរឈ្មោះបោះឆ្នោត តំណាង គ.ជ.ប បានបញ្ជាក់ជូនថា ករណីនេះជាសិទ្ធិរបស់បុគ្គល និងជាកិច្ចការរបស់គណបក្សនយោបាយ។ គណបក្សនយោបាយត្រូវតែពិនិត្យ និងរៀបចំបញ្ជីឱ្យបានត្រឹមត្រូវមុននឹងដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ នៅ គ.ជ.ប។

ពាក់ព័ន្ធនឹងអ្នកសង្កេតការណ៍អន្តរជាតិចូលរួមពិនិត្យមើលការបោះឆ្នោត តំណាង គ.ជ.ប ចាត់ទុកថាជាកិច្ចការមួយសំខាន់ ដើម្បីឆ្លុះបញ្ចាំងអំពីដំណើរការបោះឆ្នោតមានភាពត្រឹមត្រូវក្នុងកម្រិតណាមួយ។ ប៉ុន្តែក្នុងច្បាប់មិនបានចែងថា បើគ្មានអ្នកសង្កេតការណ៍បោះឆ្នោតចូលរួមទេ នោះការបោះឆ្នោតចាត់ទុកថាមិនយកជាការបានឡើយ។ ការសង្កេតការណ៍បោះឆ្នោតជាការស្ម័គ្រចិត្ត ទោះជាយ៉ាងណាក៏ដោយ គ.ជ.ប បានធ្វើការអំពាវនាវដល់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដើម្បីចូលរួមសង្កេតមើលការបោះឆ្នោត។

ចំពោះរបាយការណ៍របស់អ្នកសង្កេតការណ៍បោះឆ្នោត ឯកឧត្តម **មាន សទិ** បានសំណូមពរថា សូមអ្នកសង្កេតការណ៍ផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរ ស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងដំណើរការបោះឆ្នោតជូន គ.ជ.ប។ គ.ជ.ប មានសិទ្ធិផ្តល់យោបល់លើរបាយការណ៍នេះ។ អ្នកសង្កេតការណ៍អាចធ្វើការកែតម្រូវ ឬមិនកែតម្រូវតាមយោបល់របស់ គ.ជ.ប។ ក្នុងករណីមិនធ្វើការកែតម្រូវតាមយោបល់ គ.ជ.ប អ្នកសង្កេតការណ៍ត្រូវភ្ជាប់យោបល់នេះ នៅក្នុងផ្នែកខាងក្រោយនៃរបាយការណ៍របស់ខ្លួនដែលត្រូវធ្វើការផ្សព្វផ្សាយ។

ជាចុងក្រោយ ឯកឧត្តម **មាន សទិ** សមាជិក គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ បានបញ្ជាក់បន្ថែមថា ការបោះឆ្នោតនៅកម្ពុជាតែងតែមានអ្នកសង្កេតការណ៍អន្តរជាតិចូលរួម។ ម្យ៉ាង-ទៀត គ.ជ.ប ជាសមាជិកសមាគមនៃស្ថាប័នរៀបចំការបោះឆ្នោតពិភពលោក ហៅកាត់ថា អេវេប ( A-WEB ) និងជាសមាជិកបណ្តាញពង្រឹងសមត្ថភាពរៀបចំការបោះឆ្នោតនៃប្រទេសនិយាយភាសាបារាំង ហៅកាត់ថា រ៉េសេហ្វ ( RECEF )។ ដូចនេះ ឯកឧត្តមជឿជាក់ថា ប្រាកដជាមានអ្នកសង្កេតការណ៍អន្តរជាតិ ពីព្រោះមានការអញ្ជើញគ្នាទៅវិញទៅមក ដើម្បីចូលរួមសង្កេតមើលការបោះឆ្នោតនៅតាមបណ្តាប្រទេសដែលជាសមាជិក។

នេះជាកិច្ចប្រជុំលើកទី៣ ជាមួយភាគីពាក់ព័ន្ធក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលមានតំណាងក្រសួង-ស្ថាប័នចូលរួមមកពី ក្រុមប្រឹក្សាធម្មនុញ្ញ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការដ្ឋាននគរបាលជាតិ មន្ត្រីស្ថានទូតជប៉ុន តំណាងគណបក្សនយោបាយ តំណាងអង្គការមិនមែនរដ្ឋាភិបាល សមាគម ព្រមទាំងអ្នកសារព័ត៌មាន ចំនួនប្រមាណជិត ៥០នាក់៕

## គ.ជ.ប បើកវគ្គបណ្តុះបណ្តាលស្តីពី ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) បានបើកវគ្គបណ្តុះបណ្តាលស្តីពី ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ជូនដល់ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ( គធ.ខប ) ប្រធានលេខាធិការដ្ឋាននៃគណៈ-កម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត ( លគធ.ខប ) សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត សមាជិក គធ.ខប ដែលជាប្រធានផ្នែកអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ មន្ត្រី គ.ជ.ប តំណាងក្រសួង ស្ថាប័នជាតិ តំណាងគណបក្សនយោបាយ តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅទីស្តីការ គ.ជ.ប។

ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប ក្នុងឱកាស



ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប

អញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនេះ បានថ្លែងថា ពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត កម្ពុជាបានធ្វើការកែលម្អ និងកែទម្រង់ការបោះឆ្នោតជាបន្តបន្ទាប់ ពិសេសក្រោយការបោះឆ្នោត ឆ្នាំ២០១៣ កម្ពុជាធ្វើការកែទម្រង់ស៊ីជម្រៅមួយកម្រិតថែមទៀតទាំងលើទិដ្ឋភាពច្បាប់ ទិដ្ឋភាពបច្ចេកទេស និងស្ថាប័នរៀបចំការបោះឆ្នោត។ ឯកឧត្តមបានបន្តថា តាមរយៈការកែទម្រង់នេះ នៅឆ្នាំ២០១៤ រដ្ឋសភាបានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយដាក់បញ្ចូលស្ថាប័ន គ.ជ.ប ទៅក្នុងជំពូកទី១៥ ថ្មី(ពីរ) ហើយក្រោយមកច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើជាបន្តបន្ទាប់។

ឯកឧត្តមបានមានប្រសាសន៍បន្ថែមទៀតថា អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតថ្មី និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតនានា ចាប់តាំងពីឆ្នាំ២០១៦ មក គ.ជ.ប បានរៀបចំ ចាត់ចែង និងគ្រប់គ្រងការងារចុះឈ្មោះបោះឆ្នោត និងការ



តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាល

បោះឆ្នោត ទទួលបានលទ្ធផលជោគជ័យ និងប្រកបដោយវិជ្ជាជីវៈខ្ពស់ ដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅកម្ពុជា។

ឯកឧត្តមបានគូសបញ្ជាក់ថា ផ្អែកតាមបទពិសោធន៍ពីការបោះឆ្នោតមុនៗ និងជោគជ័យនៃការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលនៃអង្គសន្និបាតបូកសរុបការងារបោះឆ្នោតកន្លងទៅនេះ គ.ជ.ប បានពិនិត្យ និងកែលម្អការងារបច្ចេកទេសបោះឆ្នោតមួយចំនួន សំដៅរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ឱ្យកាន់តែមានភាពល្អប្រសើរថែមមួយកម្រិតទៀត តាមរយៈការអនុម័តបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣



អ្នករាជការ គ.ជ.ប ចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាល

និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីជាជំនួយដល់ដំណើរការបោះឆ្នោត។

ឯកឧត្តមអគ្គលេខាធិការ គ.ជ.ប បានលើកឡើងថា ក្រៅពីការរៀបចំការងារបច្ចេកទេសបោះឆ្នោតបានល្អប្រសើរហើយនោះ ការងារបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពរបស់មន្ត្រី គ.ជ.ប គ្រប់លំដាប់ថ្នាក់ ដែលត្រូវអនុវត្តការងារបោះឆ្នោតនាពេលខាងមុខ គឺជាកត្តាចាំបាច់។ ហេតុនេះហើយទើប គ.ជ.ប តែងតែយកចិត្តទុកដាក់រៀបចំបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីបោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់អំពីច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត នៅគ្រប់ដំណាក់កាលនៃការបោះឆ្នោត។ ជាក់ស្តែងវគ្គបណ្តុះបណ្តាលនាពេលនេះ គឺមានគោលបំណងបង្កើនសមត្ថភាព ផ្តល់ចំណេះដឹង និងជំនាញបន្ថែមទៀតពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ព្រមទាំងនីតិវិធីនៃការដាក់ ការទទួល

និងការដោះស្រាយពាក្យបណ្តឹងក្នុងដំណាក់កាលឃោសនាបោះឆ្នោត ដល់សិក្ខាកាមដែលជាមន្ត្រី គ.ជ.ប និងភាគីពាក់ព័ន្ធ ដើម្បីត្រៀមលក្ខណៈអនុវត្ត និងផ្តល់កិច្ចសហការតាមមុខការរៀងៗខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅធានាឱ្យដំណើរការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនាពេលខាងមុខប្រព្រឹត្តទៅដោយរលូន មានភាពចាស់ទុំ ក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ល្អ និងគ្មានការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

សូមជម្រាបជូនថា វគ្គបណ្តុះបណ្តាលស្តីពី ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ មានរយៈពេល ២ថ្ងៃ គឺនៅថ្ងៃទី២ និងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣៕

# វគ្គបណ្តុះបណ្តាលស្តីពីការឃោសនាបោះឆ្នោតរយៈពេល ២ថ្ងៃ ត្រូវបានបិទបញ្ចប់

នារសៀលថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ១៦:០០នាទី នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលបានប្រព្រឹត្តទៅអស់រយៈពេល ២ថ្ងៃ គឺថ្ងៃទី២ និងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣។

មានមតិសំណេះសំណាលក្នុងពិធីបិទវគ្គបណ្តុះបណ្តាលនោះ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានប្រសាសន៍ថា ដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស គ.ជ.ប បានកសាងប្រតិទិន និងផែនការមេ និងបានអនុវត្តសម្រេចការងារតាមដំណាក់កាល



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងពិធីបិទវគ្គបណ្តុះបណ្តាល**



**សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល**

នីមួយៗ ជាពិសេសការអនុម័តបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលជាឯកសារគតិយុត្តដ៏សំខាន់ សម្រាប់ការអនុវត្តការងារបច្ចេកទេសបោះឆ្នោតតាមដំណាក់កាលនីមួយៗ។

ឯកឧត្តមបានមានប្រសាសន៍បន្តទៀតថា គ.ជ.ប បានដាក់បញ្ចូលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីជំនួយដល់ការអនុវត្តដោយដៃរបស់មន្ត្រីបោះឆ្នោតឱ្យកាន់តែមានភាពងាយស្រួល ល្អប្រសើរ មានតម្លាភាព និងសុក្រឹតភាពថែមមួយកម្រិតទៀត។

ឯកឧត្តមប្រធាន គ.ជ.ប បានបន្ថែមថា ក្រៅពីការកសាងលិខិតបទដ្ឋានគតិយុត្តដែលមានលក្ខណៈល្អប្រសើរ និងគ្រប់ជ្រុងជ្រោយ ការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ព្រមទាំងភាគីពាក់ព័ន្ធឱ្យមានការយល់ដឹងច្បាស់លាស់អំពីច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត គឺជាកត្តាសំខាន់ដែល គ.ជ.ប ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យ



ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប

ហ្មត់ចត់ ហើយនេះគឺជាហេតុផលសំខាន់ នាំឱ្យមានការជួបជុំគ្នាក្នុងវគ្គបណ្តុះបណ្តាលនាពេលនេះ។ តាមរយៈវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមទាំងអស់នឹងទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីបន្ថែមទៀតពាក់ព័ន្ធនឹងដំណើរការរៀបចំការបោះឆ្នោត ជាពិសេសការឃោសនាបោះឆ្នោត ដែលត្រូវអនុវត្តពីថ្ងៃទី១ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានធ្វើការអំពាវនាវដល់គ្រប់គណបក្សនយោបាយ បេក្ខជនឈរឈ្មោះ និងអ្នកគាំទ្រទាំងអស់ត្រូវតែគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ក្រមសីលធម៌សម្រាប់ការបោះឆ្នោត គោលការណ៍ស្តីពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះ៖

- គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់មិនត្រូវបង្ខាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួនទៅហែក ឬបំផ្លាញចោលសម្ភារៈ ឯកសារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងបេក្ខជនដទៃឡើយ
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន ឬអ្នកគាំទ្រ ឬលើបុគ្គលណាម្នាក់ឡើយ
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឡើយ
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង



សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល



អ្នករាជការ គ.ជ.ប ចូលរួមក្នុងពិធីបិទវគ្គបណ្តុះបណ្តាល

ទាំងអស់ មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារ ដែលជារង្វាន់លើកទឹកចិត្ត វិភាគទាន ជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹក-ចិត្តអ្នកបោះឆ្នោត

- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់
- គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយ ដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលទាំងនោះឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ។

ចំពោះការសង្កេតការណ៍បោះឆ្នោត ឯកឧត្តមប្រធាន គ.ជ.ប បានអំពាវនាវដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដែលបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀងនៅក្នុងការឃោសនាបោះឆ្នោត និងការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានណែនាំដល់សិក្ខាកាមទាំងអស់ត្រូវយកចិត្តទុកដាក់ត្រៀមរៀបចំសម្ភារឧបទេស និងត្រៀមលក្ខណៈដើម្បីធ្វើការបណ្តុះបណ្តាលបន្តទៅមន្ត្រីបោះឆ្នោតថ្នាក់រាជធានី ខេត្ត ថ្នាក់ឃុំ សង្កាត់ ជាបន្តទៀត។

ជាចុងក្រោយ ឯកឧត្តមប្រធាន គ.ជ.ប បានអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ជួយផ្សព្វផ្សាយបន្ត ដើម្បីអប់រំដល់សាធារណជនអំពីការឃោសនាបោះឆ្នោត ព្រមទាំងចូលរួមសហការអនុវត្តតាមតួនាទី និងភារកិច្ចរៀងៗខ្លួន សំដៅធានាឱ្យដំណើរការឃោសនាបោះឆ្នោតប្រព្រឹត្តទៅក្នុងសភាពការណ៍មានសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អ មានភាពចាស់ទុំមានភាពថ្លៃថ្នូរ ចៀសវាងការជេរប្រមាថ ការញុះញង់ ការអុជអាលនាំឱ្យមានការរើសអើងទៅលើសមាជិកជាតិពន្ធុ ក្រុមជាតិ ពូជ-សាសន៍ ឬនៃសាសនាណាមួយជាកំណត់ ដើម្បីបង្កបរិយាកាសល្អដល់ដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិ-ប្រជាធិបតេយ្យ សេរីពហុបក្ស។

វគ្គបណ្តុះបណ្តាលស្តីពីការឃោសនាបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះត្រូវបាន គ.ជ.ប រៀបចំឡើងសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីបោះឆ្នោតទាំង ២៥ រាជធានី ខេត្ត ដែលមានប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ប្រធានលេខាធិការដ្ឋាននៃគណៈ-កម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត (លគធ.ខប) សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត សមាជិក គធ.ខប ដែលជាប្រធានផ្នែកអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ មន្ត្រី គ.ជ.ប តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ តំណាងគណបក្សនយោបាយ តំណាងសមាគម និងតំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលមានសិក្ខាកាមប្រមាណ ១៧៥នាក់៕

## ចំនួនអាសនៈនៃរដ្ឋសភា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅតាមមណ្ឌលបោះឆ្នោតទាំង ២៥ រាជធានី ខេត្ត

អាសនៈនៅក្នុងរដ្ឋសភាមានចំនួន ១២៥ ដែលបែងចែកតាមមណ្ឌលរាជធានី ខេត្ត ដូចខាងក្រោម៖

| | |
|---|---|
| ១. បន្ទាយមានជ័យ | ៦ អាសនៈ |
| ២. បាត់ដំបង | ៨ អាសនៈ |
| ៣. កំពង់ចាម | ១០ អាសនៈ |
| ៤. កំពង់ឆ្នាំង | ៤ អាសនៈ |
| ៥. កំពង់ស្ពឺ | ៦ អាសនៈ |
| ៦. កំពង់ធំ | ៦ អាសនៈ |

| | | | |
|---|---|---|---|
| ៧. កំពត | ៦ អាសនៈ | ១៧. សៀមរាប | ៦ អាសនៈ |
| ៨. កណ្ដាល | ១១ អាសនៈ | ១៨. ព្រះសីហនុ | ៣ អាសនៈ |
| ៩. កោះកុង | ១ អាសនៈ | ១៩. ស្ទឹងត្រែង | ១ អាសនៈ |
| ១០. ក្រចេះ | ៣ អាសនៈ | ២០. ស្វាយរៀង | ៥ អាសនៈ |
| ១១. មណ្ឌលគិរី | ១ អាសនៈ | ២១. តាកែវ | ៨ អាសនៈ |
| ១២. រាជធានីភ្នំពេញ | ១២ អាសនៈ | ២២. កែប | ១ អាសនៈ |
| ១៣. ព្រះវិហារ | ១ អាសនៈ | ២៣. ប៉ៃលិន | ១ អាសនៈ |
| ១៤. ព្រៃវែង | ១១ អាសនៈ | ២៤. ឧត្តរមានជ័យ | ១ អាសនៈ |
| ១៥. ពោធិ៍សាត់ | ៤ អាសនៈ | ២៥. ត្បូងឃ្មុំ | ៨ អាសនៈ។ |
| ១៦. រតនគិរី | ១ អាសនៈ | | |

# បេក្ខជនឈរឈ្មោះបោះឆ្នោត សហព័ទ្ធ និងកូនរបស់បេក្ខជន អាចស្នើសុំប្ដូរការិយាល័យបោះឆ្នោត សម្រាប់ការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

អនុលោមតាមមាត្រា ៤៧ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានអនុម័តយល់ព្រមឱ្យចុះបញ្ជីឈរឈ្មោះបោះឆ្នោតដោយ គ.ជ.ប ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន ដែលបានចុះឈ្មោះបោះឆ្នោតនៅមណ្ឌលបោះឆ្នោតផ្សេងពីមណ្ឌលដែលបេក្ខជនឈរឈ្មោះ អាចធ្វើសេចក្ដីស្នើសុំមក គ.ជ.ប ឱ្យផ្ទេរឈ្មោះខ្លួន ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន (ក្នុងករណីមានការយល់ព្រមពីសហព័ទ្ធ និងកូន) ទៅការិយាល័យបោះឆ្នោតណាមួយក្នុងមណ្ឌលបោះឆ្នោតដែលបេក្ខជននោះឈរឈ្មោះ។ ប្រសិនបើមានសំណើបែបនេះ គ.ជ.ប ត្រូវយល់ព្រមដោយចេញសេចក្ដីសម្រេចស្ដីពីការផ្ទេរឈ្មោះបេក្ខជន សហព័ទ្ធ និងកូន ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតដើម និងបញ្ចូលឈ្មោះអ្នកទាំងនោះទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយ ដែលស្ថិតក្នុងមណ្ឌលឈរឈ្មោះរបស់បេក្ខជននោះ។

ផ្អែកតាមសេចក្ដីជូនដំណឹងលេខ ០៣២ គ.ជ.ប ស.ជ.ណ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ការប្ដូរការិយាល័យបោះឆ្នោតរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត សហព័ទ្ធ និងកូនរបស់បេក្ខជនអនុវត្តដូចខាងក្រោម៖

- គណបក្សនយោបាយអាចធ្វើពាក្យស្នើសុំជារួមមក គ.ជ.ប ឬបេក្ខជនឈរឈ្មោះបោះឆ្នោតអាចធ្វើពាក្យស្នើសុំផ្ទាល់មក គ.ជ.ប ក៏បាន តាមគំរូទម្រង់ដែលផ្ដល់ជូនដោយ គ.ជ.ប
- ការស្នើសុំប្ដូរការិយាល័យបោះឆ្នោត ត្រូវធ្វើនៅការិយាល័យកិច្ចការគណបក្សនយោបាយ និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៃទីស្ដីការ គ.ជ.ប ជាន់ទី៩ ចាប់ពីថ្ងៃដែល គ.ជ.ប អនុម័តយល់ព្រមឱ្យចុះបញ្ជីឈរឈ្មោះ រហូតដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ ជាកំហិត។ ប្រសិនបើហួសកាលបរិច្ឆេទកំណត់នេះ គ.ជ.ប មិនទទួលខុសត្រូវក្នុងការផ្ទេរឈ្មោះបោះឆ្នោតរបស់បេក្ខជន សហព័ទ្ធ និងកូនឡើយ
- ពាក្យស្នើសុំ ត្រូវភ្ជាប់មកជាមួយនូវ៖
  - បញ្ជីរាយនាមបេក្ខជន សហព័ទ្ធ និងកូន ដែលត្រូវសុំផ្ទេរឈ្មោះចូលក្នុងការិយាល័យបោះឆ្នោតណាមួយក្នុងមណ្ឌលឈរឈ្មោះរបស់បេក្ខជន ដោយត្រូវបញ្ជាក់ឱ្យច្បាស់អំពីឈ្មោះ និងលេខកូដឃុំ សង្កាត់ លេខកូដ និងឈ្មោះទីតាំងនៃការិយាល័យបោះឆ្នោតដើម និងការិយាល័យបោះឆ្នោត

ដែលត្រូវផ្ទេរទៅ។

- លិខិតរបស់សហព័ទ្ធ និងកូន ដែលមានចុះហត្ថលេខា ឬស្នាមមេដៃបញ្ជាក់យល់ព្រមទៅបោះឆ្នោតនៅមណ្ឌលបោះឆ្នោតដែលបេក្ខជនត្រូវឈរឈ្មោះ។
- ច្បាប់ចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (សម្រាប់សហព័ទ្ធ) ឬសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (សម្រាប់កូន) របស់សាមីបេក្ខជន៕

# សិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួន ដើម្បីសង្កេតមើលការបោះឆ្នោត។

ដើម្បីធានារក្សាសណ្តាប់ធ្នាប់ របៀបរៀបរយក្នុងការបោះឆ្នោត និងដើម្បីសម្រួលដល់ការអនុវត្តភារកិច្ចដែលត្រូវចូលរួមសង្កេតមើលដំណើរការបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានកំណត់អំពីសិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ ដែលមានចែងនៅក្នុងបទបញ្ជា និងនីតិវិធី និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត។

ខាងក្រោមនេះ គឺជាកម្រងសំណួរ និងចម្លើយសង្ខេបអំពីសិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ ដែលដកស្រង់ចេញពីកម្មវិធីស្វែងយល់របស់ គ.ជ.ប ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

**សំណួរ៖ ដូចម្តេចដែលហៅថា ភ្នាក់ងារគណបក្សនយោបាយ?**

ចម្លើយ៖ អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ភ្នាក់ងារគណបក្សនយោបាយ គឺជាតំណាងដែលចាត់តាំងដោយគណបក្សនយោបាយ និងត្រូវបានអនុញ្ញាតដោយគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។ ភ្នាក់ងារគណបក្សនយោបាយ គឺជាអ្នកសង្កេតការណ៍ដែលមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ ក្នុងករណីឃើញមានភាពមិនប្រក្រតីណាមួយកើតឡើងក្នុងដំណើរការបោះឆ្នោត។

**សំណួរ៖ តើគណបក្សនយោបាយនីមួយៗ អាចដាក់ភ្នាក់ងារគណបក្សនយោបាយរបស់ខ្លួនប៉ុន្មានរូប ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត?**

ចម្លើយ៖ គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្តណាមួយ មានសិទ្ធិចាត់តាំងភ្នាក់ងារពេញសិទ្ធិរបស់ខ្លួន ១រូប និងភ្នាក់ងារបម្រុង ១រូប ដើម្បីសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗក្នុងឃុំ សង្កាត់។ ប៉ុន្តែមានតែភ្នាក់ងារពេញសិទ្ធិប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ ដោយឡែកភ្នាក់ងារបម្រុង ត្រូវអនុញ្ញាតឱ្យរង់ចាំនៅក្រៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីអវត្តមាន។

ភ្នាក់ងារគណបក្សនយោបាយ ត្រូវជាអ្នក៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ
- មានសមត្ថភាពអាចបំពេញការងារបាន តាមការធានារបស់គណបក្សនយោបាយ
- បានទទួលការបណ្តុះបណ្តាលជាភ្នាក់ងារគណបក្សនយោបាយ តាមការធានារបស់គណបក្សនយោបាយសាមី។

**សំណួរ៖ តើអ្នកណាខ្លះដែលគ្មានសិទ្ធិធ្វើជាភ្នាក់ងារគណបក្សនយោបាយ?**

ចម្លើយ៖ អ្នកដែលគ្មានសិទ្ធិធ្វើជាភ្នាក់ងារគណបក្សនយោបាយ គឺមាន បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកម្លាំងប្រដាប់អាវុធ។

**សំណួរ៖ ចំពោះគណបក្សនយោបាយដែលមានបំណងដាក់ភ្នាក់ងាររបស់ខ្លួន ដើម្បីសង្កេតការណ៍បោះឆ្នោត តើត្រូវធ្វើដូចម្តេច?**

ចម្លើយ៖ គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយមានបំណងចាត់តាំងភ្នាក់ងាររបស់ខ្លួនដើម្បីសង្កេតការណ៍បោះឆ្នោតត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៧ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការ។ សម្រាប់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ទម្រង់បែបបទ ១០០៧ គឺត្រូវផ្តល់ជូនដោយឥតគិតថ្លៃ។ គណបក្សនយោបាយអាចថតចម្លងគំរូពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ទម្រង់បែបបទ ១០០៧ នេះ ដើម្បីប្រើប្រាស់ក្នុងការដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ។ ទម្រង់បែបបទនេះក៏អាចទាញយកពីគេហទំព័រ គ.ជ.ប បាន គឺ www.nec.gov.kh។

នៅពេលដែលគណបក្សនយោបាយ ដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គឺពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយនេះ ត្រូវធ្វើជា ៣ច្បាប់ ដោយភ្ជាប់មកជាមួយនូវ៖

- បញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងសេចក្តីប្រកាសគោរពច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ច្បាប់ស្តីពីគណបក្សនយោបាយ បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត ចំនួន ៣ច្បាប់។ បញ្ជីឈ្មោះនេះ ត្រូវមានឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុង ដោយបញ្ជាក់នាមត្រកូល នាមខ្លួន ភេទ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងការិយាល័យបោះឆ្នោតដែលភ្នាក់ងារនោះត្រូវបំពេញការងារ
- លិខិតបញ្ជាក់របស់មេឃុំ ចៅសង្កាត់សាមីពាក់ព័ន្ធជាបុគ្គល ឬជាបញ្ជីដែលបញ្ជាក់ថា ភ្នាក់ងារនោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់សាមីពាក់ព័ន្ធនោះ ១ច្បាប់។

**សំណួរ៖ តើគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ ក្នុងរយៈពេលប៉ុន្មានថ្ងៃ?**

ចម្លើយ៖ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវពិនិត្យពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងចេញសេចក្តីសម្រេចអនុញ្ញាត ឬបដិសេធលើឈ្មោះភ្នាក់ងារគណបក្សនយោបាយដែលមានក្នុងបញ្ជីឈ្មោះស្នើសុំ ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ ក្រោយពីបានទទួលពាក្យស្នើសុំ។ បន្ទាប់ពីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ពិនិត្យ និងសម្រេចលើបញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចុះហត្ថលេខា និងបោះត្រាគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត លើគ្រប់ទំព័រទាំង ៣ច្បាប់ ដើម្បីផ្ញើទៅសាមីគណបក្សនយោបាយ ១ច្បាប់ ផ្ញើជូន គជ.ខប ពាក់ព័ន្ធ ១ច្បាប់ និងរក្សាទុកជាឯកសារ ១ច្បាប់។

**សំណួរ៖ ប្រសិនបើពិនិត្យលើពាក្យសុំឃើញថា ភ្នាក់ងារគណបក្សនយោបាយណាពុំមានលក្ខណសម្បត្តិត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ តើគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើដូចម្តេច?**

ចម្លើយ៖ ប្រសិនបើគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

ពិនិត្យលើពាក្យសុំឃើញថា ភ្នាក់ងារគណបក្សនយោបាយណាម្នាក់ពុំមានលក្ខណសម្បត្តិត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅតំណាងសាមីគណបក្សនយោបាយ ហើយត្រូវគូសបន្ទាត់លុបលើឈ្មោះភ្នាក់ងារ ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងចារនៅខាងចុងឈ្មោះ ត្រង់ខ្ទង់ផ្សេងៗ ដោយបញ្ជាក់ពីមូលហេតុ ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ ក្រោយពីបានទទួលពាក្យសុំ។ គណបក្សនយោបាយមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងរបស់ខ្លួនជាថ្មីមួយលើកទៀត ជំនួសឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងដែលបានបដិសេធមកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងអំពីការបដិសេធនេះ។ ក្នុងរយៈពេលនេះ ប្រសិនបើតំណាងគណបក្សនយោបាយនៅតែពុំព្រមកែតម្រូវតាមលក្ខខណ្ឌដូចបានកំណត់ទេ នោះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវសម្រេចទទួលស្គាល់តែឈ្មោះភ្នាក់ងារគណបក្សនយោបាយណាដែលបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌតែប៉ុណ្ណោះ។ បន្ទាប់ពីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត សម្រេចអនុញ្ញាតលើពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងបោះត្រាគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតនៅលើជ្រុងខាងស្តាំផ្នែកខាងក្រោមនៃរូបថត និងផ្តល់ជូនភ្នាក់ងារនោះ ដើម្បីពាក់ក្នុងពេលបំពេញការងារ។

**សំណួរ៖ តើភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ចអ្វីខ្លះក្នុងដំណើរការបោះឆ្នោត?**

ចម្លើយ៖ ភ្នាក់ងារគណបក្សនយោបាយ ដែលសង្កេតមើលក្នុងដំណើរការបោះឆ្នោត មានសិទ្ធិ និងភារកិច្ចដូចជា៖

- ត្រូវមានវត្តមាននៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែលខ្លួនបានទទួលការអនុញ្ញាត តាមទីកន្លែងដែលបានកំណត់ដោយគណៈកម្មការការិយាល័យបោះឆ្នោត ឬគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ឬ គ.ជ.ប និងត្រូវចុះបញ្ជីវត្តមាន
- ចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតបានតែម្នាក់ប៉ុណ្ណោះ។ ភ្នាក់ងារបម្រុងត្រូវរង់ចាំនៅខាងក្រៅការិយាល័យ ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីមានការផ្លាស់ប្តូរ
- ជំទាស់ ឬតវ៉ារាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធី ដែលខ្លួនបានឃើញផ្ទាល់។ ការជំទាស់ ឬការតវ៉ា ត្រូវធ្វើឡើងទៅប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការជំទាស់ ឬការតវ៉ាអាចលើកឡើងដោយផ្ទាល់មាត់ ឬ/និងទៅតាមទម្រង់បែបបទរបស់ គ.ជ.ប
- ចុះហត្ថលេខាលើរបាយការណ៍ ឬកំណត់ហេតុផ្សេងៗ ដែលកំណត់ដោយ គ.ជ.ប
- ចុះហត្ថលេខា ឬផ្តិតមេដៃនៅលើកំណត់ហេតុនៃការបោះឆ្នោត (ទម្រង់បែបបទ ១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទ ១១០២)
- មានសិទ្ធិទទួលបានកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទ ១១០២)
- ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក
- ប្តឹងជំទាស់ ឬប្តឹងតវ៉ាស្របទៅតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញថាមានភស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការបោះឆ្នោត
- ទទួលបានដោយស្មើភាពគ្នាក្នុងការការពារសន្តិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានាក្នុងដំណើរការបោះឆ្នោត។

**សំណួរ៖ តើភ្នាក់ងារគណបក្សនយោបាយ អាចថតរូបនៅក្នុង**

**ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតបានដែរ ឬទេ?**

ចម្លើយ៖ ភ្នាក់ងារគណបក្សនយោបាយ មិនអាចប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗនៅក្នុងការិយាល័យបោះឆ្នោតបានទេ។ ប៉ុន្តែភ្នាក់ងារគណបក្សនយោបាយ អាចថតយកសកម្មភាពនៅក្នុងការិយាល័យបោះឆ្នោត ក្រោយការប្រកាសបិទការបោះឆ្នោត ដោយសុំការអនុញ្ញាតពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ប៉ុន្តែមិនត្រូវបង្កការរំខានផ្សេងៗណាមួយ ដែលធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាននោះទេ។ ចំពោះនៅការិយាល័យរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយអាចថតរូបភាពបាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការរាប់សន្លឹកឆ្នោតឡើយ៕

# តំណាង គ.ជ.ប ជួបពិភាក្សាការងារជាមួយ តំណាងក្រុមហ៊ុនហ្គូហ្គល (Google)

យោងតាមសំណើរបស់តំណាងក្រុមហ៊ុនហ្គូហ្គល (Google) និងដោយមានការអនុញ្ញាតពី ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប នៅរសៀលថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ១៥:៣០ នាទី ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប



ឯកឧត្តម ហង្ស ពុទ្ធា សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប

រួមជាមួយថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានជំនាញ គ.ជ.ប បានទទួលជួបជាមួយលោក **អ៊ីវ ហ្គោនស្សាឡេស** (Mr. Yves Gonzalez) តំណាងក្រុមហ៊ុនហ្គូហ្គល (Google) ប្រចាំនៅអាស៊ីអាគ្នេយ៍ មានការិយាល័យនៅប្រទេសសិង្ហបុរី ដើម្បីពិភាក្សាអំពីកិច្ចសហការជាមួយគ្នា លើការទប់ស្កាត់ព័ត៌មានក្លែងក្លាយ និងព័ត៌មានខុសច្បាប់។

លោក **អ៊ីវ ហ្គោនស្សាឡេស** បានមានប្រសាសន៍ថា បន្ទាប់ពីលោកបានជួបជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍រួចមក លោកមានបំណងជួប គ.ជ.ប ដើម្បីឱ្យមានកិច្ចសហការល្អជាមួយគ្នា ក្នុងការចូលរួមទប់ស្កាត់ព័ត៌មានក្លែងក្លាយ និងព័ត៌មានខុសច្បាប់ក្នុងបណ្តាញសង្គម។ ដើម្បីធ្វើការងារនេះបាន សុំបង្កើតក្រុមការងារទំនាក់ទំនងគ្នារវាង គ.ជ.ប ជាមួយនឹងតំណាងក្រុមហ៊ុនហ្គូហ្គល (Google) ដែលមានទីស្នាក់ការប្រចាំនៅរាជធានីភ្នំពេញ ដើម្បីដោះស្រាយបញ្ហាបានទាន់ពេល។

បន្ទាប់ពីបានពិភាក្សាគ្នាលើបញ្ហាបច្ចេកទេសជាច្រើនលើផ្នែកព័ត៌មានវិទ្យារួចមក ក្នុងជំនួបពិភាក្សានោះ ឯកឧត្តម **ហង្ស ពុទ្ធា** បានស្នើឱ្យក្រុមហ៊ុនហ្គូហ្គល (Google) សហការជាមួយ គ.ជ.ប លើការងារមួយចំនួន៖

- បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកទីតាំងការិយាល័យបោះឆ្នោត នៅលើហ្គូហ្គល (Google) ឱ្យមានប្រសិទ្ធភាព
- ទប់ស្កាត់ការលួចទិន្នន័យព័ត៌មានដោយខុសច្បាប់
- ដកចេញខ្លឹមសារព័ត៌មានលើបណ្តាញសង្គម យូធូប



លោក អ៊ីវ ហ្គោនស្សាឡេស តំណាងក្រុមហ៊ុន Google

(YouTube) ក្នុងករណី គ.ជ.ប ពិនិត្យឃើញថា មានការរំលោភបំពាន ធ្វើឱ្យប៉ះពាល់ដល់ការបោះឆ្នោតនៅកម្ពុជា ។ល។

លោក **អ៊ីវ ហ្គោនស្សាឡេស** បានទទួលយករាល់ការលើកឡើងទាំងអស់របស់តំណាង គ.ជ.ប ហើយបញ្ជាក់ថា កិច្ចសហការទាំងនេះមិនតម្រូវឱ្យបង់ថ្លៃសេវាទេ។

ជាចុងក្រោយ ឯកឧត្តម **ហង្ស ពុទ្ធា** មានប្រសាសន៍ថា ឯកឧត្តមនឹងរាយការណ៍ជូន គ.ជ.ប អំពីជំនួបនេះ ហើយការសុំបង្កើតក្រុមការងារទំនាក់ទំនង គឺទុកជូន គ.ជ.ប សម្រេច។

ជំនួបពិភាក្សាការងារបានប្រព្រឹត្តទៅអស់រយៈពេលប្រមាណមួយម៉ោង ប្រកបដោយភាពស្និទ្ធស្នាល និងយោគយល់គ្នា៕



សកម្មភាពក្នុងជំនួបពិភាក្សា

# រូបភាពសកម្មភាពនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣



គណបក្សប្រជាជនកម្ពុជា



គណបក្សយុវជនកម្ពុជា



គណបក្សធម្មាធិបតេយ្យ



គណបក្ស ខ្មែររួបរួមជាតិ



គណបក្សកម្លាំងប្រជាធិបតេយ្យ



គណបក្សសញ្ញាតិកម្ពុជា



គណបក្សខ្មែរតែមួយ



គណបក្សខ្មែរអភិរក្ស



គណបក្សហ៊្វុនស៊ិនប៉ិច



គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ



គណបក្សបំណងពលរដ្ឋ



គណបក្សឯកភាពជាតិខ្មែរ



គណបក្សស្ត្រីដើម្បីស្ត្រី



គណបក្សខ្មែរឈប់ក្រ



គណបក្ស ភ្លើងទៀន



គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច



គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា



គណបក្សប្រជាធិបតេយ្យមូលដ្ឋាន



គណបក្សមហាសាមគ្គីជាតិខ្មែរ



គណបក្សកសិករ

រៀបរៀង និងបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ទីស្តីការ គ.ជ.ប វិថីវង្សសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីមែល(Email): info@nec.gov.kh
Website: www.nec.gov.kh, voterlist.nec.gov.kh
Facebook/Youtube: National Election Committee
APP: NEC KH, CamNEC News